# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៨ និងទិសដៅការងារឆ្នាំ២០០៩

## របស់ធនាគារជាតិនៃកម្ពុជា

**នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១១-១២ ខែមីនា ឆ្នាំ២០០៩**

**សូមគោរព :**

**- លោកជំទាវ ទេសាភិបាលរង**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា !**

មកដល់ពេលនេះ អង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៨ និងទិសដៅការងារឆ្នាំ២០០៩ របស់យើង បានចូលមកដល់ពេលវេលាដែលត្រូវបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អង្គសន្និបាតបានប្រព្រឹត្តទៅយ៉ាងសកម្ម និងដោយរលូនរហូតដល់ទីបញ្ចប់ដោយជោគជ័យ ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ ពិតជាក្តាប់បានពីសភាពការណ៍រួមនៃសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក នៅឆ្នាំ២០០៨ ហើយទន្ទឹមនេះ ក៏បានស្តាប់នូវខ្លឹមសារសំខាន់ៗនៃបទឧទ្ទេសនាម បទអន្តរាគមន៍ អនុសាសន៍ណែនាំផ្សេងៗ និង*ជាពិសេស* ទិសដៅការងារដែលត្រូវបន្តអនុវត្តនៅពេលអនាគត ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម និងលោក លោកស្រី ដែលបានផ្តល់បទឧទ្ទេសនាមយ៉ាងក្បោះក្បាយ និងអនុសាសន៍ល្អៗ ហើយក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិក-សមាជិកានៃអង្គសន្និបាតទាំងអស់ ដែលបានអញ្ជើញមកចូលរួម និងបានខិតខំយកចិត្តទុកដាក់ស្តាប់បទឧទ្ទេសនាម និងមានវត្តមាននៅក្នុងអង្គសន្និបាតនេះ តាំងពីដើមដល់ចប់ ។

ក្នុងរយៈពេលពីរថ្ងៃនេះ បន្ទាប់ពី លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាបានស្តាប់ខ្លឹមសារសំខាន់នៃលទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជានៅឆ្នាំ២០០៨ និងបទឧទ្ទេសនាមសំខាន់ៗទាក់ទងនឹងការងារគ្រប់គ្រងសាច់ប្រាក់-ឃ្លាំងបេឡា ការងារសវនកម្មនិងអធិការកិច្ច ការងារគ្រប់គ្រងទុនបំរុងនិងការអភិវឌ្ឍប្រព័ន្ធទូទាត់ ការត្រួតពិនិត្យធនាគារ បទអន្តរាគមន៍របស់សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ការងារប្រតិបត្តិការ និងការងារទំនាក់ទំនងអន្តរជាតិរួចមក ថ្ងៃនេះ ខ្ញុំសូមលើកឡើងនូវមតិមួយចំនួនបន្ថែមទៀត ដើម្បីជាការផ្តាំផ្ញើដល់

មន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខាខេត្ត-ក្រុងអំពីអ្វី ដែលធនាគារជាតិនៃកម្ពុជា ត្រូវធ្វើនៅពេលអនាគត ដូចតទៅ :

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

តួនាទីចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺត្រូវរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកគាំទ្រស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព ។ *ដូច្នេះ* ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជា គឺនៅតែបន្តពង្រឹងតួនាទីរបស់ខ្លួនក្នុងការដឹកនាំនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន និងមានលក្ខណៈទន់ភ្លន់ទៅតាមការវិវត្តន៍ជាក់ស្តែងនៃសេដ្ឋកិច្ច និងស៊ីគ្នាជាមួយនឹងគោលនយោបាយសារពើពន្ធ ។

សុខភាពនៃប្រព័ន្ធធនាគារ ក៏ជាកត្តាមួយសំខាន់សំរាប់គាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចផងដែរ *ដូច្នេះ* គោលការណ៍អភិបាលកិច្ច និងការត្រួតពិនិត្យសុខភាពប្រព័ន្ធធនាគារ គឺជាវិធានការណ៍ចាំបាច់តម្រូវឱ្យយើងត្រួតពិនិត្យជាប់ជាប្រចាំ និងប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ។

**១. ការងារបេឡា** ជាការងារបច្ចេកទេសទាមទារជំនាញទាក់ទងទៅនឹង : *ទី១*-ការត្រួតពិនិត្យការរាប់ស្រាល់ជ្រើសប្រភេទរូបិយវត្ថុ និងរូបិយប័ណ្ណតាមការណែនាំ *ទី២*-ការគ្រប់គ្រង និងថែរក្សាសាច់ប្រាក់ឱ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និង*ទី៣*-ការពារសុវត្ថិភាពឃ្លាំងប្រាក់ ។ កិច្ចការនេះអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព តម្រូវឱ្យមន្ត្រីទាំងអស់បន្តប្រកាន់ខ្ជាប់នូវសីលធម៌ ភាពស្មោះត្រង់ វិន័យការងារ និងគោរពតាមការចាត់តាំងត្រឹមត្រូវ ។

**២. ការងារសវនកម្មផ្ទៃក្នុង :** យើងនឹងបន្តធ្វើសវនកម្មផ្ទៃក្នុងនៅតាមនាយកដ្ឋាន និងសាខារបស់យើងមួយចំនួនទៀត តាមកម្មវិធីគ្រោងទុក ព្រមទាំងចុះទៅធ្វើអធិការកិច្ចដោយឆ្លក់នៅតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងមួយចំនួនទៀត ។ ដើម្បីដំណើរការងារនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព យើងបន្តបណ្តុះបណ្តាលមុខជំនាញ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិថែមទៀត ។ នាយកដ្ឋាន និងសាខាខេត្ត-ក្រុងមួយចំនួនបានប្រតិបត្តិបានល្អហើយ ត្រូវខិតខំធ្វើឱ្យកាន់តែល្អថែមទៀត ហើយបើនាយកដ្ឋាន និងសាខាខេត្ត-ក្រុងណាដែលនៅមានកង្វះខាត ដូចរបាយការណ៍នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានលើកឡើង ត្រូវខិតខំកែលំអការងាររបស់ខ្លួនឱ្យកាន់តែសុក្រឹតឡើង ។

**៣. ការងារត្រួតពិនិត្យធនាគារ :** យើងបន្តពង្រឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងកម្មវិធីកុំព្យូទ័រ COBRA ឱ្យកាន់តែមានភាពសុក្រឹតថែមទៀត ។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នឹងជួយឱ្យធនាគារនីមួយៗឱ្យទទួលបានព័ត៌មានច្បាស់លាស់ពីអតិថិជនរបស់ខ្លួន មុននឹងសំរេចចិត្តផ្តល់ឥណទានអាចការពារបាននូវហានិភ័យអសាធនភាពរបស់អ្នកសុំខ្ចីប្រាក់ និងកាត់បន្ថយឥណទានមិនដំណើរការ (NPL) ក្នុងប្រព័ន្ធធនាគារទៀតផង ។ យើងអនុវត្តកម្មវិធីកុំព្យូទ័រ COBRA ក្នុងគោលបំណងធ្វើឱ្យការត្រួតពិនិត្យលើឯកសារឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពសំរាប់ការវិភាគ និងវាយតម្លៃស្ថានភាពធនាគារ ឱ្យកាន់តែសុក្រឹតឡើង ។ យើងកំពុងធ្វើការកែលំអបទប្បញ្ញត្តិមួយចំនួន ដើម្បីឱ្យការអនុវត្តស្របតាមយន្តការទីផ្សារបច្ចុប្បន្ន ។

៤). **ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** (FIU) : ការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម យើងត្រូវរៀបចំក្របខ័ណ្ឌគតិយុត្តដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រទេសក្នុងតំបន់ និងពិភពលោកសំដៅគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបនូវរាល់ប្រតិបត្តិការ ឬបទល្មើសដែលទាក់ទងនឹងប្រតិបត្តិការ សំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព ។ នៅឆ្នាំ២០០៩ នេះ យើងចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយធនាគារកណ្តាលម៉ាឡេស៊ី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងបណ្តុះបណ្តាលធនធានមនុស្ស ។

៥). **ការងារប្រតិបត្តិការធនាគារ** គឺជាការងារអាទិភាពរបស់យើង ។ យើងត្រូវអនុវត្តការងារនេះឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការបើក និងគ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ ចាប់ពីថ្នាក់ក្រសួងរហូតដល់ថ្នាក់មូលដ្ឋានឃុំ-សង្កាត់ ។ យើងបាន និងកំពុងកែលំអកន្លែងធ្វើការងារ និងពង្រីកប្រតិបត្តិការសភាផាត់ទាត់នៅតាមតំបន់ និងខេត្ត-ក្រុងមួយចំនួន ដូចជានៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងបន្ទាយមានជ័យ ដែលជាតំបន់មានសក្តានុពលសេដ្ឋកិច្ច ដើម្បីជួយសម្រួលដល់សកម្មភាពសេដ្ឋកិច្ច ហើយយើងនឹងបន្តធ្វើនៅតាមខេត្តមួយចំនួនទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងរបស់ភ្នាក់ងារសេដ្ឋកិច្ច ។

៦). **ការងារគ្រប់គ្រងទុនបំរុង** ជាភារកិច្ចសំខាន់របស់ធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពថ្លៃ និងសុវត្ថិភាពប្រព័ន្ធធនាគារ ។ ដោយសារបច្ចុប្បន្នយើងប្រឈមមុខនឹងវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ យើងត្រូវបន្តគ្រប់គ្រងទុនបំរុងអន្តរជាតិដោយឈរលើគោលការណ៍ប្រុងប្រយ័ត្ន ធានាសុវត្ថិភាព និងចំណូលបន្ថែមទៀត ។

៧). **ការងារប្រព័ន្ធទូទាត់និងផាត់ទាត់ :** បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងរៀបចំបំពាក់ប្រព័ន្ធធនាគារស្នូល (Core Banking System) ដើម្បីធ្វើស្វ័យប្រវត្តិកម្មនូវរាល់ប្រតិបត្តិការរបស់នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានគណនេយ្យដែលជានាយកដ្ឋានស្នូល ។ ប្រព័ន្ធទូទាត់ត្រូវបានអភិវឌ្ឍ ដែលក្នុងនោះសភាផាត់ទាត់មូលប្បទានប័ត្រ ការគ្រប់គ្រងប្រតិបត្តិការទូទាត់រាយ និងប្រតិបត្តិការទូទាត់នូវទឹកប្រាក់ធំៗ ដោយប្រព័ន្ធអេឡិចត្រូនិក (RTGS) ត្រូវធ្វើទំនើបកម្មជាបណ្តើរៗ នៅទីស្នាក់ការកណ្តាល ។ ទៅអនាគត យើងនឹងរៀបចំបំពាក់ប្រព័ន្ធនេះនៅតាមសាខាខេត្ត-ក្រុងចាំបាច់មួយចំនួនទៀត ។

៨). **ការងារគណនេយ្យ** ជាការងារជំនាញបច្ចេកទេស ទាក់ទងនឹងកិច្ចចុះបញ្ជិកានូវរាល់ប្រតិបត្តិការធនាគារ *ដូច្នេះ* ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមប្លង់គណនីឯកភាពរបស់ធនាគារជាតិនៃកម្ពុជា ។ ចំពោះសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងមួយចំនួន ដែលមានកង្វះខាតលើការងារចុះកិច្ចបញ្ជិកាទ្រព្យសម្បត្តិ ត្រូវខិតខំកែលំអកិច្ចបញ្ជិការបស់ខ្លួនឱ្យកាន់តែសុក្រឹតឡើង បើសាខាខេត្ត-ក្រុងណា ដែលប្រតិបត្តិបានល្អហើយ ត្រូវបន្តពង្រឹងឱ្យកាន់តែល្អប្រសើរថែមទៀត ។

៩).**ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង និងការបង្កើនជំនឿទុកចិត្តលើប្រាក់រៀល** គឺជាការងារអាទិភាពរបស់យើង ។ យើងបានពង្រីកប្រតិបត្តិការសាខារបស់យើងនៅទូទាំង

ប្រទេស ដើម្បីជួយសំរួលដល់ការងារចរាចរសាច់ប្រាក់រៀល ការបែងចែកសាច់ប្រាក់រៀល និងគ្រប់គ្រងប្រតិ-បត្តិការធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតាមតំបន់ *ជាពិសេស* គឺចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងការបើកគណនី និងគ្រប់គ្រងសេវាគណនីរបស់រដ្ឋទាំងអស់ចាប់ពីថ្នាក់ឃុំ-សង្កាត់ដល់ថ្នាក់ក្រសួងសម្រាប់ការផ្ទេរសាច់ប្រាក់ទូទាត់ពាណិជ្ជកម្ម បង់ពន្ធអាករ និងបើកប្រាក់-បៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធទូទាំងប្រទេស ជាប្រាក់រៀល ។ ចំពោះការពង្រឹងជំនឿទុកចិត្តលើប្រាក់រៀល យើងត្រូវបន្តលើកកម្ពស់វិធានការបច្ចុប្បន្នក្នុងការបើកប្រាក់ខែ ជូនមន្ត្រីរាជការ ការបង់ពន្ធគ្រប់ប្រភេទ និងការបង់ថ្លៃសេវាទឹកភ្លើងជាប្រាក់រៀល ហើយយើងនឹងបន្ត ជម្រុញឱ្យវិស័យមីក្រូហិរញ្ញវត្ថុផ្តល់សេវាជាប្រាក់រៀលឱ្យប្រព្រឹត្តទៅកាន់តែច្រើនឡើង កាន់តែរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

១០). **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥** ត្រូវបានរាជរដ្ឋាភិបាលអនុម័តយកធ្វើជាផែនទីគោចរសំរាប់ពង្រឹងមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍ និងពង្រីកវិស័យធនាគារនិងហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមគោលដៅអភិវឌ្ឍន៍សហវត្សរបស់រាជរដ្ឋាភិបាល ។ ធនាគារជាតិនៃកម្ពុជា ដែលជាលេខាធិការដ្ឋានផង និងជាភ្នាក់ងារអនុវត្តផង ត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្រនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

១១). **ការងារសហប្រតិបត្តិការក្នុងតំបន់ :** ជាមួយ SEACEN យើងបន្តបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា និងវគ្គសិក្សាផ្សេងៗ ដើម្បីធ្វើការបណ្តុះបណ្តាល និងផ្លាស់ប្តូរបទពិសោធន៍គ្នាក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ។ យើងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយធនាគារកណ្តាលនៅក្នុងតំបន់ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុឱ្យមានប្រសិទ្ធភាព ។ យើងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលកូរ៉េ វៀតណាម ឡាវ និងធនាគារកណ្តាលជាមិត្តផ្សេងទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៃការគ្រប់គ្រងធនាគារកណ្តាល ការបណ្តុះបណ្តាលធនធានមនុស្ស និងផ្លាស់ប្តូរមន្ត្រីជំនាញមកធ្វើការនៅធនាគារជាតិនៃកម្ពុជាលើផ្នែកអាទិភាពមួយចំនួន ។

១២). **ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក :** កត្តាដែលមានធនធានមនុស្សសំបូរបែបគឺជាគន្លឹះសំរាប់ដោះស្រាយការលំបាកទាំងនោះ ។

ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ដែលយើងអនុវត្តកន្លងមក ឈរលើគោលការណ៍បួនគឺ :

- លើកផែនការសម្រិតសម្រាំងមន្ត្រីចូលថ្មី ត្រូវឆ្លងកាត់តាមរយៈការប្រលងប្រជែងលើមុខជំនាញ
- លើកកម្ពស់គុណភាពធនធានមនុស្សដែលមានស្រាប់ខាងផ្នែកជំនាញឯកទេស
- លើកកម្ពស់គុណភាពធនធានមនុស្សខាងផ្នែកគុណធម៌ សីលធម៌ និងវិន័យការងារ
- លើកកម្ពស់គុណភាពធនធានមនុស្សខាងផ្នែកសុខមាលភាព និងអត្ថប្រយោជន៍ខាងផ្នែកសង្គមកិច្ច ។

ជាទិសដៅ ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា គឺជាការងារអាទិភាពដែលយើងត្រូវធ្វើជាប្រចាំនៅនឹងកន្លែង និងបញ្ជូនទៅចូលរួមវគ្គសិក្សារយៈពេលវែងនិងខ្លីនៅបរទេស ដើម្បីលើកកម្ពស់សមត្ថភាព

និងគុណភាពការងារមន្ត្រីរបស់យើងទាំងខាងឯកទេសកម្ម ការទទួលខុសត្រូវចំពោះការងារ ភាសាបរទេស វិន័យការងារ និងការប្រតិបត្តិសីលធម៌ក្នុងការងារ ។ *សរុបមក* បើយើងមានធនធានមនុស្សល្អ គឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក និងគ្រប់វិស័យ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា !**

នៅឆ្នាំ២០០៩ និង២០១០ ខាងមុខនេះ ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជានឹងត្រូវ :

១- រៀបចំពិធីបុណ្យខួបទី ៣០ឆ្នាំ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-២០០៩) បន្ទាប់ពីរបបប៉ុលពតបំផ្លាញចោល ដើម្បីរំលឹក និងអបអរសាទរចំពោះសមិទ្ធផលដែលយើងបានសហការរួមគ្នាកសាងជាមួយរដ្ឋាភិបាលចាប់ពីឆ្នាំ១៩៧៩ កន្លងមក

២- ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាគំរូអន្តរជាតិ (Typologies Workshop) របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការប្រឆាំង និងការសម្អាតប្រាក់នៅកម្ពុជា និងមានការចូលរួមពីប្រទេសជាសមាជិកចំនួន ១៨០ ប្រទេស និង

៣- នៅឆ្នាំ២០១០ យើងត្រូវធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (SEACEN) លើកទី៤៥ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល SEACEN លើកទី២៩ និងមានការចូលរួមពីទេសាភិបាល SEACEN ចំនួន ១៦ប្រទេស ប្រទេសសង្កេតការណ៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយចំនួនទៀត ។

មតិដែលខ្ញុំបានលើកឡើងខាងលើ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាយើង ត្រូវអនុវត្តចំពោះមុខសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងទៅអនាគត សំដៅបន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង និងពង្រឹងប្រព័ន្ធធនាគារទាំងមូលឱ្យមានសុវត្ថិភាព មានប្រសិទ្ធភាព និងទទួលបានការ ជឿទុកចិត្តពីសាធារណជនជាតិ-អន្តរជាតិបន្ថែមទៀត ។ ការណ៍នេះសម្រេចទៅបាន គឺទាល់តែមានការចូលរួមយ៉ាងសកម្មពីកម្លាំងសរុប និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីមន្ត្រីរបស់យើងគ្រប់ជាន់ថ្នាក់ ។

ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងជាលក្ខណៈប្រពៃណីរបស់យើងថែមទៀត ដើម្បីអនុវត្តការងារទាំងនេះឱ្យបានជោគជ័យ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីគោរព !**

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើបីចំណុចដូចខាងក្រោម :

១- សូមថ្នាក់ដឹកនាំគ្រប់ផ្នែកទាំងអស់នៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវខិតខំអនុវត្តទិសដៅការងារឆ្នាំ២០០៩របស់ធនាគារជាតិនៃកម្ពុជាឱ្យបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់

២- ត្រូវពង្រឹងការងារសវនកម្មផ្ទៃក្នុង ឱ្យស្របតាមគោលការណ៍អភិបាលកិច្ចល្អ

៣- ត្រូវបន្តបណ្តុះបណ្តាល និងពង្រីកសមត្ថភាពមន្ត្រីបុគ្គលិកទាំងសមត្ថភាពការងារ និងគុណធម៌ ។

ជាចុងក្រោយ ខ្ញុំសូមឱ្យសមាជិក សមាជិកា ដែលជាថ្នាក់ដឹកនាំមកពីនាយកដ្ឋាននានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិខេត្ត-ក្រុងទាំងអស់ដែលបានចូលរួមក្នុងសន្និបាតពេលនេះ នៅពេលដែលត្រឡប់ទៅបំរើការងារវិញ ត្រូវយកស្មារតី និងលទ្ធផលនៃអង្គសន្និបាតរបស់យើង ទៅប្រជុំផ្សព្វផ្សាយឱ្យមន្រ្តីបុគ្គលិករបស់ខ្លួនបានជ្រួតជ្រាប ដើម្បីរួមចំណែកអនុវត្តការងារនេះបានប្រព្រឹត្តទៅដោយរលូន ទទួលបានជោគជ័យ និងមានប្រសិទ្ធភាព ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្រ្តីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលដ៏ល្អ និងបានកសាងប្រព័ន្ធធនាគារឱ្យទទួលបាននូវការទុកចិត្តរបស់សាធារណជនជាតិ និងអន្តរជាតិ ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងសន្និបាត និងមានវត្តមានតាំងពីដើមដល់ចប់ ។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ !**